ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៤៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្លាស់ប្តូរចំណាត់ថ្នាក់ប្រើប្រាស់ដីរដ្ឋ ដោយផ្ទេរពីមុខងារដីបរិវេណ អាកាសយានដ្ឋានក្រចេះ ទៅគោលដៅសម្រាប់សាងសង់សាកលវិទ្យាល័យក្រចេះ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- យោងតាមតម្រូវការចាំបាច់

## ស ម្រេ ច

**មាត្រា១:-**

ត្រូវបានផ្លាស់ប្តូរចំណាត់ថ្នាក់ប្រើប្រាស់ដីរដ្ឋ ដោយផ្ទេរពីមុខងារដីបរិវេណអាកាសយានដ្ឋានក្រចេះ ទៅគោលដៅសម្រាប់សាងសង់សាកលវិទ្យាល័យក្រចេះ ដែលមានផ្ទៃដីទំហំ ៩៩,០១ ហិកតា ជាក្បាលដីទី១

ស្ថិតនៅផ្នែកខាងត្បូង ផ្លូវជាតិលេខ ៧ ដូចមានប្លង់លេខ ០៩៦៧ /៩៨ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ១៩៩៨ និង សេចក្តីបញ្ជាក់លេខ ៤៤៩ ចណ ក្រច ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៨ របស់អភិបាលខេត្តក្រចេះ ព្រមទាំងមាន និយាមកាដូចខាងក្រោម ÷

| | | |
|---|---|---|
| C1 | E6-14-823 | N13-81-685 |
| C2 | E6-14-659 | N13-81-378 |
| C3 | E6-14-438 | N13-81-497 |
| C4 | E6-14-202 | N13-81-056 |
| C5 | E6-14-422 | N13-80-938 |
| C6 | E6-13-831 | N13-79-836 |
| C7 | E6-14-184 | N13-79-647 |
| C8 | E6-15-237 | N13-81-610 |

**មាត្រា២: -**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣: -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ